ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

~~~

-ក្រសួងការពារជាតិ

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ក្រសួងសុខាភិបាល

-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា

លេខ :

# សារាចរណែនាំអន្តរក្រសួង

## ស្តីពី

## ការអនុវត្តអនុក្រឹត្យលេខ០៨ អនក្រ.បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០០៧ ស្តីពីរបបឧបត្ថម្ភចំពោះយោធិនពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងពិការ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា
នាយកដ្ឋាន និង បុគ្គលិក
លេខ.......
ថ្ងៃទី 23 ខែ 5 ឆ្នាំ 2007
បញ្ជូន.......

ដើម្បីអនុវត្តអនុក្រឹត្យលេខ ០៨ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០០៧ ស្តីពីរបបឧបត្ថម្ភចំពោះយោធិនពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងពិការ ឱ្យមានប្រសិទ្ធភាព អន្តរក្រសួងរួមមាន ក្រសួងការពារជាតិ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល សូមធ្វើសារាចរណែនាំអនុវត្តនូវចំណុចសំខាន់ៗដូចខាងក្រោម :

## ផ្នែកទី ១

## ការរៀបចំចាត់តាំង និងភារកិច្ច របស់ក្រុមប្រឹក្សាវាយតម្លៃប្រភេទថ្នាក់ពិការ

I-ក្រសួងការពារជាតិ ត្រូវបង្កើតក្រុមប្រឹក្សាវាយតម្លៃប្រភេទថ្នាក់ពិការ ដើម្បីវាយតម្លៃរបួសពិការជូនយោធិនរបួសពិការឱ្យបានត្រឹមត្រូវតាមកម្រិតប្រភេទថ្នាក់ពិការ ដែលក្រសួងសុខាភិបាលបានកំណត់ ។

ក្រុមប្រឹក្សាវាយតម្លៃប្រភេទថ្នាក់ពិការរួមមាន ៣ថ្នាក់ ដូចខាងក្រោម :

- ថ្នាក់ក្រសួង
- ថ្នាក់យោធភូមិភាគ
- ថ្នាក់តំបន់ប្រតិបត្តិការសឹករងខេត្ត-ក្រុង

II -**សមាសភាពក្រុមប្រឹក្សាវាយតម្លៃ** :

ក- **ថ្នាក់ក្រសួងការពារជាតិ** :

១-ប្រធាន ១រូប ជាវេជ្ជបណ្ឌិត និងជាប្រធានមន្ទីរពេទ្យព្រះកេតុមាលា ។

២-អនុប្រធាន ១រូប ជាមន្ត្រីតំណាងក្រសួងសុខាភិបាល ។

៣-អនុប្រធាន ១រូប ជាមន្ត្រីតំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។
~~~

៤-សមាជិក ១រូប ជានាយទាហានទទួលការងារពិការ របស់ក្រសួងការពារជាតិ ។

៥-សមាជិក ១រូប ជាវេជ្ជបណ្ឌិតផ្នែកវះកាត់ ។

៦-សមាជិក ១រូប ជាវេជ្ជបណ្ឌិតផ្នែកជំងឺទូទៅ ។

៧-លេខាធិការ ១រូប ជានាយទាហានទទួលបន្ទុកគោលនយោបាយមន្ទីរពេទ្យព្រះកេតុមាលា ។

ខ. ថ្នាក់យោធភូមិភាគ :

១-ប្រធាន ១រូប ជាមេបញ្ជាការ ឬមេបញ្ជាការរង របស់យោធភូមិភាគ ។

២-អនុប្រធាន ១រូប ជាមន្ត្រីរបស់មន្ទីរសុខាភិបាលខេត្ត-ក្រុង (ខេត្ត-ក្រុង ដែលយោធភូមិភាគបោះទីតាំងឈរជើង) ។

៣-អនុប្រធាន ១រូប ជាមន្ត្រីតំណាងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ខេត្ត-ក្រុង ដែលយោធភូមិភាគបោះទីតាំងឈរជើង ) ។

៤-សមាជិក ១រូប ជានាយទាហានទទួលការងារគោលនយោបាយពលី ពិការ របស់យោធភូមិភាគ ។

៥-សមាជិក ១រូប ជាវេជ្ជបណ្ឌិតផ្នែកវះកាត់ របស់មន្ទីរពេទ្យយោធភូមិភាគ ។

៦-សមាជិក ១រូប ជាវេជ្ជបណ្ឌិតផ្នែកជម្ងឺទូទៅ របស់មន្ទីរពេទ្យយោធភូមិភាគ ។

៧-លេខាធិការ ១រូប ជានាយទាហានជំនួយការគោលនយោបាយពលី ពិការ របស់យោធភូមិភាគ ។

គ. ថ្នាក់តំបន់ប្រតិបត្តិការសឹករងខេត្ត-ក្រុង :

១-ប្រធាន ១រូប ជាមេបញ្ជាការ ឬមេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងខេត្ត-ក្រុង ។

២-អនុប្រធាន ១រូប ជាមន្ត្រី របស់មន្ទីរសុខាភិបាលខេត្ត-ក្រុង ។

៣-អនុប្រធាន ១រូប ជាមន្ត្រីតំណាងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត-ក្រុង ។

៤-សមាជិក ១រូប ជានាយទាហានទទួលការងារគោលនយោបាយពលី ពិការ របស់តំបន់ប្រតិបត្តិការសឹករងខេត្ត-ក្រុង ។

៥-សមាជិក ១រូប ជាវេជ្ជបណ្ឌិតផ្នែកវះកាត់ របស់មន្ទីរពេទ្យខេត្ត-ក្រុង ។

៦-សមាជិក ១រូប ជាវេជ្ជបណ្ឌិតផ្នែកជម្ងឺទូទៅ របស់មន្ទីរពេទ្យខេត្ត-ក្រុង ។

៧-លេខាធិការ ១រូប ជានាយទាហានជំនួយការគោលនយោបាយពលី ពិការ របស់តំបន់ប្រតិបត្តិការសឹករងខេត្ត-ក្រុង ។

III. ភារកិច្ច និងសិទ្ធិរបស់ក្រុមប្រឹក្សាវាយតម្លៃប្រភេទថ្នាក់ពិការ :

ក. ភារកិច្ច :

ក្រុមប្រឹក្សាវាយតម្លៃប្រភេទថ្នាក់ពិការ របស់ក្រសួងការពារជាតិ យោធភូមិភាគ និងតំបន់ប្រតិបត្តិការសឹករងខេត្ត-ក្រុង មានភារកិច្ចពិនិត្យវាយតម្លៃកំណត់ប្រភេទថ្នាក់ពិការជូនដល់យោធិនពិការក្រោមឱវាទ

របស់ខ្លួនឱ្យបានត្រឹមត្រូវតាមលក្ខណៈកម្រិតប្រភេទថ្នាក់ពិការ ដែលក្រសួងសុខាភិបាលបានកំណត់ ។

ខ. សិទ្ធិ :

ក្រុមប្រឹក្សាវាយតម្លៃប្រភេទថ្នាក់ពិការមានសិទ្ធិដូចតទៅ :

-មានសិទ្ធិចេញវិញ្ញាបនប័ត្របញ្ជាក់ប្រភេទថ្នាក់ពិការជូនយោធិនជម្ងឺ របួស ពិការ ក្រោមឱវាទរបស់ខ្លួន ។

-ករណីយោធិនរបួសជំងឺប្តឹងតវ៉ាសុំពិនិត្យកម្រិតប្រភេទថ្នាក់ពិការឡើងវិញនោះ ក្រុមប្រឹក្សាវាយតម្លៃប្រភេទថ្នាក់ពិការនៃសាមីជននោះ ត្រូវរៀបចំសំណុំលិខិតឯកសារពាក់ព័ន្ធព្រមទាំងវិញ្ញាបនប័ត្របញ្ជាក់ប្រភេទថ្នាក់ពិការនោះបញ្ជូនមកក្រុមប្រឹក្សាវាយតម្លៃប្រភេទថ្នាក់ពិការ របស់ក្រសួងការពារជាតិ ដើម្បីធ្វើការពិនិត្យសម្រេចឡើងវិញ ។

-កំណត់ របបសម្រាកប៉ំប៉នសុខភាព ។

-លើកជាសំណូមពរជូនអង្គភាពគ្រប់គ្រងយោធិនពិការឱ្យរៀបចំការងារជូនយោធិនរបួសពិការជំងឺសមស្របតាមលទ្ធភាពសុខភាព របស់យោធិនពិការ របួស ជំងឺ ។

IV- <u>របៀបរបបការងារ របស់ក្រុមប្រឹក្សាវាយតម្លៃប្រភេទថ្នាក់ពិការ</u> :

១-ក្រុមប្រឹក្សាវាយតម្លៃប្រភេទថ្នាក់ពិការគ្រប់ថ្នាក់ ត្រូវទទួលយកយោធិនពិការមកធ្វើការពិនិត្យវាយតម្លៃប្រភេទថ្នាក់ពិការ ក្រោយពេលយោធិនទាំងនោះបានព្យាបាលជំងឺរបួសជាសះស្បើយ និងមានលំនឹងរួចហើយដោយភ្ជាប់មកជាមួយនូវ :

-លិខិតទទួលស្គាល់របួសពិការ ចេញដោយសាមីកងឯកភាព ។

-លិខិតអនុញ្ញាតចេញពីមន្ទីរពេទ្យ ។

-សំណុំលិខិតបញ្ជាក់ពីលទ្ធផលព្យាបាល ។

២-ពេលប្រជុំពិនិត្យវាយតម្លៃកំណត់សម្រេចប្រភេទថ្នាក់ពិការ ជំងឺ ត្រូវមានសមាសភាពក្រុមប្រឹក្សាវាយតម្លៃប្រភេទថ្នាក់ពិការ ៥ ភាគ ៧ ឡើងទៅ ។

## <u>ផ្នែកទី ២</u>

## <u>ការផ្ទេរប្រគល់សំណុំលិខិតយោធិនពលី មរណៈ ពិការ ពីក្រសួងការពារជាតិ ទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា</u>

I -<u>ការកំណត់ការកិច្ច</u> :

- ការផ្ទេរប្រគល់សំណុំលិខិតយោធិនពលី មរណៈ និងពិការគឺត្រូវធ្វើដោយក្រសួងការពារជាតិជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

- នាយកដ្ឋានកិច្ចការយោធា.ស៊ីវិលនៃក្រសួងការពារជាតិ និងនាយកដ្ឋានសោធនអតីតយុទ្ធជន នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវទទួលខុសត្រូវរាល់សំណុំលិខិតដែលត្រូវផ្ទេរប្រគល់ ពីក្រសួងការពារជាតិទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

- មុនពេលការផ្ទេរប្រគល់ ក្រសួងការពារជាតិ ត្រូវបើកប្រាក់ឧបត្ថម្ភមួយលើកដំបូងជូនដល់ គ្រួសារយោធិនពលី មរណៈ ។

- បើកប្រាក់បៀវត្សបញ្ចេញពីជួរកងយោធពលខេមរភូមិន្ទ ប្រាក់ជំនួយមុខរបួស និងប្រាក់អតីត ភាពជូនដល់យោធិនពិការ ដើម្បីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបើកប្រាក់ឧបត្ថម្ភមួយ លើកដំបូងវិលទៅមូលដ្ឋាន និងបៀវត្សប្រចាំខែ ។

II -<u>របៀបបំពេញសំណុំលិខិត និងសម្រេចទទួលស្គាល់យោធិនពលី មរណៈ និងពិការ</u> :

ក- ចំពោះយោធិនពិការ ដែលប្រកាសឱ្យចេញពីជួរកងយោធពលខេមរភូមិន្ទ ត្រូវកសាងសំណុំលិខិត ដូចខាងក្រោម :

១- លិខិតផ្ទេរយោធិនពិការពីក្រសួងការពារជាតិទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនី-តិសម្បទាចំនួន ០២ ច្បាប់ ចេញដោយក្រសួងការពារជាតិ ។

២- ប្រកាសចេញពីជួរកងយោធពលខេមរភូមិន្ទចំនួន ០២ ច្បាប់ ចេញដោយក្រសួង ការពារជាតិ ។

៣- បញ្ជីរាយនាមយោធិនពិការចំនួន ០២ ច្បាប់ ចេញដោយនាយកដ្ឋានកិច្ចការយោធា.ស៊ីវិល នៃក្រសួងការពារជាតិ ។

៤- លិខិតទទួលស្គាល់យោធិនត្រូវរបួស ពិការចំនួន ០២ ច្បាប់ ចេញដោយកងឯកភាពដើម និង មានបញ្ជាក់ទទួលស្គាល់ពីនាយកដ្ឋានកិច្ចការយោធា.ស៊ីវិល នៃក្រសួងការពារជាតិ ។

៥- វិញ្ញាបនប័ត្របញ្ជាក់ប្រភេទថ្នាក់ពិការ ( មានបិទរូបថត ៤ x ៦ ) ចំនួន ០២ ច្បាប់ចេញ ដោយក្រុមប្រឹក្សាវាយតម្លៃប្រភេទថ្នាក់ពិការ ។

៦- លិខិតឧទ្ទេសនាមផ្តត់ផ្គង់ហិរញ្ញវត្ថុចំនួន ០២ ច្បាប់ ចេញដោយនាយកដ្ឋានកិច្ចការយោធា. ស៊ីវិលនៃក្រសួងការពារជាតិ ។

៧- ជីវប្រវត្តិសង្ខេប របស់យោធិនពិការចំនួន ០២ ច្បាប់ ដោយបញ្ជាក់ទទួលស្គាល់ពីកងឯកភាព ដើម ។

៨- លិខិតចម្លងប្រកាសចេញពីជួរកងយោធពលខេមរភូមិន្ទចំនួន ០២ ច្បាប់ ។

៩- រូបថតទំហំ ៣ x ៤ ចំនួន ០៤ សន្លឹក ។

ខ- ចំពោះយោធិនពលី មរណៈ ត្រូវបំពេញសំណុំលិខិតដូចមានខាងក្រោម :

១- លិខិតផ្ទេរយោធិនពលី មរណៈ ពីក្រសួងការពារជាតិទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាចំនួន ០២ ច្បាប់ ចេញដោយក្រសួងការពារជាតិ ។

២- ប្រកាសចេញពីជួរកងយោធពលខេមរភូមិន្ទចំនួន ០២ ច្បាប់ ចេញដោយក្រសួងការពារជាតិ ។

៣- បញ្ជីរាយនាមយោធិនពលី មរណៈ ចំនួន០២ ច្បាប់ ចេញដោយនាយកដ្ឋានកិច្ចការយោធា.ស៊ីវិលនៃក្រសួងការពារជាតិ ។

៤- លិខិតបញ្ជាក់ទទួលស្គាល់យោធិនពលី មរណៈ ចំនួន ០២ ច្បាប់ ចេញដោយកងឯកភាពដើម និងមានបញ្ជាក់ទទួលស្គាល់ពីនាយកដ្ឋានកិច្ចការយោធា.ស៊ីវិលនៃក្រសួងការពារជាតិ ។

៥- លិខិតឧទ្ទេសនាមផ្គត់ផ្គង់ហិរញ្ញវត្ថុចំនួន ០២ ច្បាប់ ចេញដោយនាយកដ្ឋានកិច្ចការយោធា.ស៊ីវិលនៃក្រសួងការពារជាតិ ។

៦- សេចក្តីចម្លងជីវប្រវត្តិសង្ខេប របស់យោធិនពិការចំនួន ០២ ច្បាប់ ដោយបញ្ជាក់ទទួលស្គាល់ពីកងឯកភាពដើម ។

## ផ្នែកទី ៣

## ការចើកប្រាក់ឧបត្ថម្ភចំពោះគ្រួសារពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងយោធិនពិការ

I -ការគំណត់ភារកិច្ច :

រៀងរាល់ឆ្នាំក្រសួងការពារជាតិ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវធ្វើគំរោងផែនការចំណាយប្រាក់ឧបត្ថម្ភជូនដល់យោធិនពលី មរណៈ និងពិការ ស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួនមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

១-ក្រសួងការពារជាតិ :

- ត្រូវបើកប្រាក់ឧបត្ថម្ភជូនគ្រួសារពលី មរណៈ បង្កស្លាប់ និងយោធិនពិការដូចខាងក្រោម :

ក-ចំពោះយោធិនពលី មរណៈ និងបង្កស្លាប់ :

- ប្រាក់បូជាសព ឬ បញ្ចុះសព ។

- ប្រាក់ឧបត្ថម្ភជូនយោធិនពលី មរណៈ បង្កស្លាប់ មួយលើកដំបូង ។

ខ-ចំពោះយោធិនពិការ :

- ប្រាក់បំប៉នសុខភាព និងប្រាក់ជំនួយមុខរបួសជូនយោធិនពិការ ដែលរស់នៅក្នុងមណ្ឌលបំប៉នពិការ ។

- ប្រាក់ជំនួយមុខរបួស របស់យោធិនពិការកំពុងបន្តធ្វើការងារក្នុងកងយោធពលខេមរភូមិន្ទ ។

- ប្រាក់បៀវត្សបញ្ចេញពីជួរកងយោធពលខេមរភូមិន្ទ និងប្រាក់ឧបត្ថម្ភអតីតភាពជូនយោធិនពិការមុនពេលផ្ទេរទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

**២. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា :**

- បើកប្រាក់ឧបត្ថម្ភមួយលើកដំបូង និងបន្តបើកប្រាក់បៀវត្សសរុបប្រចាំខែជូនដល់យោធិនពិការ ។

- បន្តបើកប្រាក់ឧបត្ថម្ភជំនួយគ្រួសារប្រចាំខែជូនដល់ប្រពន្ធ ឬ ប្តី កូនបង្កើត ឪពុក ម្តាយបង្កើត ឬអ្នកអាណាព្យាបាល របស់យោធិនពលី មរណៈ ។

- ក្នុងករណីរាជរដ្ឋាភិបាលតម្លើងប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗដល់មន្ត្រីរាជការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវតម្លើងប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភជូនដល់ជនពិការដូចគ្នា ។

- ចំពោះជនពិការប្រភេទ " ក " គ្រប់ថ្នាក់ដែលទទួលមរណៈភាពមានលិខិតបញ្ជាក់មរណៈភាពពីអាជ្ញាធរមូលដ្ឋាន ត្រូវទទួលស្គាល់ជាជនពលី និងត្រូវដោះស្រាយប្រាក់ឧបត្ថម្ភមួយលើកដំបូងនៃប្រាក់ឧបត្ថម្ភគោលនយោបាយប្រចាំខែ និងប្រាក់បូជាសព ហើយផ្ទេរមកទទួលប្រាក់ឧបត្ថម្ភពលីវិញ ។

- ចំពោះប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភប្រចាំខែ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវធ្វើផែនការចំណាយឡើងទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យមុនថ្ងៃទី ២០នៃខែមុន ដើម្បីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុផ្តល់ថវិកាឱ្យទាន់ពេលវេលា ។

**៣. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ :**

ក្រោយពេលដែលក្រសួងការពារជាតិ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ធ្វើអាណត្តិសុំបើកប្រាក់ឧបត្ថម្ភដែលមានភ្ជាប់នូវសំណុំលិខិតយុត្តិការគ្រប់គ្រាន់ត្រឹមត្រូវហើយនោះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រួតពិនិត្យ និងផ្តល់ទិដ្ឋាការជាបន្ទាន់ ដើម្បីក្រសួងការពារជាតិ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អនុវត្តការបើកប្រាក់ឧបត្ថម្ភទាន់ពេលវេលា ។

**II .ការបើកប្រាក់ឧបត្ថម្ភ :**

- បណ្តាគ្រួសារពលី មរណៈ និងយោធិនពិការ ដែលត្រូវមកបើកប្រាក់ឧបត្ថម្ភ ត្រូវមានឈ្មោះក្នុងប្រកាសទទួលស្គាល់ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមានសំណុំបែបបទភ្ជាប់មកជាមួយ ។

- បណ្តាគ្រួសារពលី មរណៈ និងយោធិនពិការ ដែលមិនទាន់ផ្ទេរទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន ដែលមកបើកប្រាក់ឧបត្ថម្ភគោលនយោបាយ ត្រូវមានប្រកាសទទួលស្គាល់ពីក្រសួងការពារជាតិ ។

- បណ្តាគ្រួសារយោធិនពលី មរណៈ និងយោធិនពិការណា ដែលមានធុរៈធ្ងន់ធ្ងរមិនអាចមកបើក

ប្រាក់ឧបត្ថម្ភ និងប្រាក់បៀវត្សបាន ត្រូវមានលិខិតផ្ទេរសិទ្ធ និងលិខិតបញ្ជាក់ពីមូលហេតុច្បាស់លាស់ ហើយមានការបញ្ជាក់ពីអាជ្ញាធរដែនដី និងអង្គភាពគ្រប់គ្រងផ្ទាល់ ។

## ជំពូកទី ៤

## វិធានការចាត់តាំងអនុវត្ត

ដើម្បីធានាចាត់តាំងអនុវត្តឱ្យមានប្រសិទ្ធភាព សម្រេចលទ្ធផលល្អប្រសើរ គ្រប់អង្គភាពដែលមានការពាក់ព័ន្ធ ត្រូវយកចិត្តទុកដាក់លើចំណុចសំខាន់ៗ ដូចខាងក្រោម :

១. **កំណត់ចំពោះការវាយតម្លៃប្រភេទថ្នាក់ពិការ** :

ការកំណត់កម្រិតប្រភេទថ្នាក់ពិការ ជាការងារមួយមានសារសំខាន់ក្នុងការអនុវត្តនីគោលនយោបាយ របស់រាជរដ្ឋាភិបាលចំពោះយោធិនពិការ និងជាភារកិច្ចមួយស្មុគស្មាញទាក់ទងទៅនឹងការងារបច្ចេកទេសវេជ្ជសាស្ត្រ ទាមទារអនុវត្តឃ្មត់ចត់ និងត្រឹមត្រូវបំផុត ។

២. **ការងារផ្ទេរប្រគល់** :

- ការផ្ទេរប្រគល់ត្រូវធ្វើតាមវគ្គបាល ធម្មតាពីក្រសួងការពារជាតិមកក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដោយមានសំណុំលិខិតរបស់មុខសញ្ញាភ្ជាប់មកជាមួយ ។

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រោយពេលបានទទួលសំណុំលិខិតត្រឹមត្រូវពីក្រសួងការពារជាតិយ៉ាងយឺតបំផុត ៩០ ថ្ងៃ ត្រូវចេញប្រកាសទទួលស្គាល់ ។

៣. **ការបើកប្រាក់ឧបត្ថម្ភ** :

- ការបើកប្រាក់ឧបត្ថម្ភជូនគ្រួសារពលី មរណៈ និងយោធិនពិការ ត្រូវបើកជូនដល់ដៃត្រឹមត្រូវ តាមរបបកំណត់ដោយមានការផ្តិតស្នាមមេដៃ ឬចុះហត្ថលេខាទទួលស្គាល់ប្រាក់ពីសាមីជន ។

៤. **ប្រជុំដកពិសោធន៍** :

- ក្នុងការអនុវត្តនីដោះស្រាយគោលរបបឧបត្ថម្ភចំពោះគ្រួសារពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងយោធិនពិការ បើមានបញ្ហាណាមិនច្បាស់ ធ្វើឱ្យរាំងស្ទះការងារ អង្គភាពជំនាញ ត្រូវលើកជាមតិជូនក្រសួងការពារជាតិ ឬ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឬក្រសួងសុខាភិបាល ឬក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នូវករណីដែលមានការពាក់ព័ន្ធ ដើម្បីប្រជុំពិភាក្សាដោះស្រាយបានទាន់ពេលវេលា ។

- រៀងរាល់ត្រីមាស អន្តរក្រសួងរួមមាន ក្រសួងការពារជាតិ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល ត្រូវចាត់តាំងប្រជុំដកពិសោធនីការងារ ។

- រៀងរាល់ឆ្នាំ ត្រូវចាត់តាំងធ្វើសិក្ខាសាលាបូកសរុបដកពិសោធនីក្នុងការអនុវត្តនីព្រមទាំង

ℓ

លើកឡើងនូវទិសដៅឱ្យបានសមស្របទៅតាមសភាពការណ៍រីកចំរើន របស់ប្រទេសជាតិ ។

## ផ្នែកទី ៥

ផ្អែកតាមសារាចរណែនាំអន្តរក្រសួងនេះ ក្រសួងនីមួយៗ ត្រូវធ្វើសារាចរណែនាំដោយឡែក សម្រាប់ណែនាំដល់បណ្ដាអង្គភាព និងកងឯកភាពក្រោមឱវាទផ្ទាល់ និងខ្សែបណ្ដោយរបស់ខ្លួន ដើម្បីអនុវត្តសារាចរនេះឱ្យមានប្រសិទ្ធភាពតាមភារកិច្ចរៀងៗខ្លួន ។

## ផ្នែកទី ៦

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ៦ ឆ្នាំ ២០០៧

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

រដ្ឋមន្ត្រីក្រសួងការពារជាតិ

តាបខ.ផ្កាយមាស៥ ទៀ-បាញ់

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

អ៊ិត សំហេង

រដ្ឋមន្ត្រីក្រសួងសុខាភិបាល

វេជ្ជ. នុត-សុខុម